-លោកឧត្តម ម៉ែង គឹមលី ជាអគ្គលេខាធិការរងនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើ និង អនុរដ្ឋលេខាធិការ ។

មាត្រា ២ ._ ក្រុមប្រឹក្សាធម្មនុញ្ញនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៨

ព្រះហស្ថលេខា

នរោត្តម សីហនុ

★ ★ ★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៤២ អនក្រ.បក

### ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៨

-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

### សំរេច

មាត្រា ១ ._ ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញស្ថិត ក្រោមអំណាចប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អោយទទួលបន្ទុករៀបចំចាត់ចែងការងារ ធ្វើកំណត់ហេតុ ទទួលរ៉ាប់រងផងដែរ នូវគ្រប់កិច្ចការរដ្ឋបាលរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

www.pheakdeylaw.com

មាត្រា ២ .‒ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដឹកនាំដោយអគ្គលេខាធិការម្នាក់ និង អគ្គលេខាធិការរងម្នាក់ ជាអ្នកជំនួយការ នៅក្រោមការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។ អគ្គលេខាធិការដឹកនាំបញ្ជា ការងាររដ្ឋបាលក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការអាចទទួលសិទ្ធិពីប្រធាន ដើម្បីចុះហត្ថលេខាលើលិខិត ឬសេចក្ដីសំរេចរដ្ឋបាល ។ អគ្គលេខាធិការ និង អគ្គលេខាធិការរង ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់ មានបទពិសោធន៍ក្នុងកិច្ចការ រដ្ឋបាលយ៉ាងតិច១០ឆ្នាំ ហើយដែលមិនមែនជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និង មិនមែនជាអ្នកដឹកនាំក្នុងគណៈបក្សនយោបាយណាមួយ ។

មាត្រា ៣ .‒ អគ្គលេខាធិការ និង អគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្ដីស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលមានវត្តមាន ។ អគ្គលេខាធិការ និង អគ្គលេខាធិការរង មានឋានៈស្មើនឹង រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ ។

មាត្រា ៤.‒ អគ្គលេខាធិការដ្ឋាន ត្រូវចែកជានាយកដ្ឋាន រដ្ឋបាល ហិរញ្ញកិច្ច និង នាយកដ្ឋានច្បាប់និតិវិធីកម្ម និង ស្រាវជ្រាវ ។ នាយកដ្ឋានចែកជាការិយាល័យ ។

នៅក្នុងរយៈពេលដំបូង ដែលបើកអោយចាប់ផ្ដើមការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើស តែងតាំងបុគ្គលិកទាំងអស់ នៃអគ្គលេខាធិការដ្ឋានតាមសំណើរបស់អគ្គលេខាធិការ ។

បុគ្គលិកទាំងអស់ អាចជ្រើសរើសថ្មី ឬផ្ទេរពីស្ថាប័នរដ្ឋផ្សេងៗទៀតក៏បាន ។ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ មានប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀតស្មើនឹងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

មាត្រា ៥ .‒ ចំណាយសំរាប់ការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយប្រធាន ក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អាចផ្ទេរសិទ្ធិនេះជូនអគ្គលេខាធិការជាអាណាប័កផ្ទេរសិទ្ធិ ។

គណនេយ្យករម្នាក់ត្រូវបានតែងតាំង ដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អោយទទួលបន្ទុកបើកអាណត្តិបើកប្រាក់ ។

មាត្រា ៦ .‒ ឯកសារឯកសារទាំងអស់ និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋានហើយមិនត្រូវធ្វើអោយចេញក្រៅ ដោយគ្មានការអនុញ្ញាតពី ប្រធានឡើយ។

មាត្រា ៧ .‒ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨ .‒ ទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមប្រឹក្សាធម្មនុញ្ញ និង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន